# គោលការណ៍បណ្តឹងសម្ងាត់

**មាតិការគោលការណ៍:** គោលការណ៍បណ្តឹងសម្ងាត់
**កាលបរិច្ឆេទអនុម័ត:** ខែមករា ឆ្នាំ២០២៣
**កាលបរិច្ឆេទពិនិត្យឡើងវិញ**: ខែមករា ២០២៤
**អនុម័តដោយ:** Patrice Davison, នាយិកាប្រតិបត្តិ

**គោលបំណងនៃគោលការណ៍៖** អង្គការអនាគតកុមារអន្តរជាតិ (CFI) ត្រូវប្រកាន់ខ្ជាប់នូវស្តង់ដានៃការគ្រប់គ្រង និងក្រមសីលធម៌របស់អង្គការ រួមបញ្ចូលទាំងការអនុវត្តគោលការណ៍ទាំងអស់ ដែលអនុម័តដោយអង្គភាព។ ជាពិសេស គោលការណ៍ការការពារកុមារ និងគោលការណ៍ PSEA គឺជាកត្តាសំខាន់បំផុតក្នុងការធានាថាកុមារ និង សហគមន៍ ដែល CFI ធ្វើការជាមួយមានសុវត្ថិភាព។ លើសពីនេះ CFI ត្រូវតែរក្សាគាំទ្រគោលការណ៍ហិរញ្ញវត្ថុ និងគោលការណ៍ប្រឆាំងអំពើពុករលួយផ្សេងៗទៀត ក្នុងការធានានូវសុខុមាលភាពនៃស្ថាប័ន ដើម្បីរក្សា CFI ឲ្យនូវតែអាចបន្តមាននិរន្តរភាព។ ដើម្បីរក្សាគោលការណ៍ទាំងនេះ ការអនុវត្តត្រូវតែមាន ដែលក្នុងនោះមានទាំងរបៀបមួយច្បាស់លាស់សម្រាប់ ការរាយការណ៍ និងវិធីសាស្ត្រមួយដែលបុគ្គលិក កុមារ និងសមាជិកក្នុងសហគមន៍ មានអារម្មណ៍សុវត្ថិភាព និងមានទំនុកចិត្តក្នុងការប្រើប្រាស់នូវរបៀបរាយការណ៍ទាំងនោះ។

**និយមន័យ** ៖ បណ្តឹងសម្ងាត់ គឺជាការរាយការណ៍ រឺលាតត្រដាងនូវរាល់ព័តមាន ឬសកម្មភាពទាំងឡាយណាដែលខុសច្បាប់ គ្មានក្រមសីលធម៌ ដែលប្រឆាំងនឹងគោលការណ៍របស់អង្គការ (ឧទាហរណ៍៖ ការក្លែងបន្លំ អំពើពុករលួយ ការរំលោភបំពាន នឹង គោលការណ៍ PSEA ជាដើម -ល-។)

**វិសាលភាពនៃគោលការណ៍៖** គោលការណ៍នេះមានវិសាលភាពអនុវត្តចំពោះអ្នកពាក់ព័ន្ធទាំងអស់របស់ អង្គការអនាគតកុមារអន្តរជាតិ ដូចជានាយក មន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្ត បុគ្គលិកហាត់ការ អនាគតនិយោជិក សមភាគី អ្នកប្រឹក្សា អ្នកម៉ៅការ សមាជិកអង្គការដៃគូរ និងភ្ញៀវ។ ចាប់ពីពេលនេះតទៅ ពាក្យថា "សហការីCFI" នឹងត្រូវបានប្រើប្រាស់ ដើម្បីតំណាងឲ្យក្រុមទាំងនេះ ដែលគោលការណ៍នេះពាក់ព័ន្ធ និងអាចអនុវត្តទៅបាន។

**គោលការណ៍៖**
សហការីទាំងអស់របស់ CFI ត្រូវបានរំពឹងទុកថា នឹងធ្វើសកម្មភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់នៅក្នុងប្រទេសកម្ពុជា រួមទាំងច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់ ដែលអាចអនុវត្តទៅបានរបស់សហរដ្ឋអាមេរិច ផងដែរ ( ឧ.ច្បាប់ហិរញ្ញវត្ថុ/ច្បាប់ពន្ធដា និង ក្រម ៥០១c៣ ជាដើម -ល-។) ជាមួយនឹងគោលការរបស់ CFI គ្រប់ពេលទាំងអស់ ក្នុងការធានាថា CFI បានដំណើរការធុរកិច្ច និងកិច្ចការរបស់ខ្លួនឲ្យស្របតាមស្តង់ដាក្រមសីលធម៌ខ្ពស់បំផុត។
សហការី CFI ណាក៏ដោយដែលបានចូលរួម ឬមានការសង្ស័យដោយសមហេតុផលថា សហការី CFI ផ្សេងៗទៀត មានការជាប់ពាក់ព័ន្ធក្នុងការបំពានច្បាប់ បទប្បញ្ញត្តិ វិធានក្រមសីលធម៌ ឬគោលនយោបាយណាមួយរបស់ CFI ត្រូវតែរាយការណ៍ពីសកម្មភាពនោះឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន។ សកម្មភាពទាំងនោះមានដូចជា

ការធ្វើខុសផ្នែកហិរញ្ញវត្ថុ (រួមទាំងការគេចវេសពីការត្រួតពិនិត្យផ្ទៃក្នុង
ឬការរំលោភលើគោលការណ៍ហិរញ្ញវត្ថុរបស់អង្គការ) ការក្លែងបន្លំ ការបៀតបៀន ការប្រព្រឹត្តខុសច្បាប់
ឬគ្មានក្រមសីលធម៌ផ្សេងទៀតផងដែរ។

**ដំណើរការនៃការាយការណ៍៖**
ប្រសិនបើការបំពាននេះមានជាប់ពាក់ព័ន្ធនឹង ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ នោះគោលការណ៍ (PSEA) គួរតែត្រូវបានអនុវត្ត រួមទាំងការប្រើប្រាស់វិធីសាស្រ្តរាយការណ៍ និងឧបករណ៍ ដែលមានចែងក្នុងគោលនយោបាយនេះ។

ប្រសិនបើការបំពាននោះជាបញ្ហាក្រមសីលធម៌មិនជាប់ទាក់ទងនឹងគោលការណ៍ (PSEA) ទេ សហការី CFI ទាំងអស់ អាចរាយការណ៍តាមរយៈប្រអប់សំបុត្រផ្តល់យោបល់ ឬទៅអ្នកគ្រប់គ្រងរបស់ពួកគេ ឬនាយកគ្រប់គ្រងរបស់ CFI ណាមួយ។ ប្រសិនបើការព្រួយបារម្ភណ៍នេះទាក់ទងនឹងនាយក CFI ឬសមាជិកក្រុមប្រឹក្សាភិបាលណាមួយ នោះការរាយការណ៍អាចត្រូវបានធ្វើឡើងទៅកាន់ប្រធានក្រុមប្រឹក្សាភិបាល។ (សូមមើលឧបសម្ព័ន្ធ 1)

បុគ្គលណាដែលទទួលរបាយការណ៍បែបនេះ ត្រូវបញ្ជូនវាទៅនាយកប្រតិបត្តិ ដែលនឹងត្រូវតែបញ្ជូនវាបន្តទៅកាន់ ប្រធានក្រុមប្រឹក្សាភិបាលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ របាយការណ៍អាចត្រូវបានធ្វើឡើងដោយអនាមិក ទោះជាយ៉ាងណាក៏ដោយ កាតព្វកិច្ចក្នុងការរាយការណ៍អំពីការរំលោភលើច្បាប់ បទប្បញ្ញត្តិ ឬគោលនយោបាយរបស់ CFI
គឺមិនពេញចិត្តតាមរយៈការរាយការណ៍ដោយបុគ្គលអំពីការរំលោភបំពានផ្ទាល់ខ្លួនរបស់គាត់ឬនាងដោយអនាមិកនោះទេ
។

ការរាយការណ៍ទាំងអស់ នឹងត្រូវបានធ្វើការស៊ើបអង្កេត និងដោះស្រាយឲ្យទាន់ពេលវេលា ដោយមានការយកចិត្តទុកដាក់ខ្ពស់។  បុគ្គលដែលបានរាយការណ៍ នឹងទទួលបានការបញ្ជាក់ថា របាយការណ៍របស់គេ នឹងត្រូវបានដាក់ឲ្យស៊ើបអង្កេតក្នុងរយៈពេលមួយសប្តាហ៍ ( មិនចាំបាច់ជាលទ្ធផលដែលបានពីការស៊ើបអង្កេតនោះទេ)។ ការរក្សាការសម្ងាត់ នឹងត្រូវបានរក្សាជូនក្នុងអំឡុងពេលនៃការស៊ើបអង្កេត ក្នុងកម្រិតសមហេតុផល និង អាចអនុវត្តន៍ ទៅបានក្រោមកាលៈទេសៈជាក់ស្តែង ហើយស្របជាមួយនឹងសកម្មភាពស៊ើបអង្កេតច្បាសលាស់ និងត្រឹមត្រូវ។

សកម្មភាពអវិជ្ជមាននានានឹងមិនមានចំពោះការងារ
ឬការសងសឹកផ្សេងទៀតប្រឆាំងនឹងបុគ្គលណាម្នាក់ដែលរាយការណ៍ពីការបំពាន ដែលសង្ស័យ
ឬជួយក្នុងការស៊ើបអង្កេតនោះទេ លើកលែងតែក្នុងករណីដែល CFI
កំណត់ថារបាយការណ៍មិនពិតត្រូវបានធ្វើឡើងក្នុងចេតនាធ្វើឱ្យប៉ះពាល់ដល់ស្ថាប័ន ឬបុគ្គលនៅក្នុងស្ថាប័ន។

ការបំភិតបំភ័យ ការបង្ខិតបង្ខំ ការគំរាមកំហែង ឬការរើសអើងប្រឆាំងនឹងបុគ្គលណាម្នាក់ដែលរាយការណ៍ថាមាន ការសង្ស័យថាមានកំហុស ត្រូវបានហាមឃាត់ ហើយនឹងត្រូវទទួលរងនូវវិធានការវិន័យយ៉ាងតឹងរឹង ដែលអាចរួមបញ្ចូល ការបញ្ចប់ការងារ។

## 7 គន្លឹះសម្រាប់អ្នកប្តឹងសម្ងាត់

1. **<u>និយាយដោយគ្មានការភ័យខ្លាច</u>**

- CFI នឹងធានាថា អ្នកប្តឹងសម្ងាត់ ត្រូវបានការពារ ហើយមិនត្រូវបានគំរាមកំហែងទេ ប្រសិនបើការបង្ហាញនោះ ស្របតាមគោលការណ៍ និងស្មោះត្រង់ ទោះបីជាការចោទប្រកាន់ត្រូវបានរកឃើញថាមិនពិតក៏ដោយ ។
- រាល់ព័ត៌មានណាដែលបានផ្តល់ឱ្យ នឹងត្រូវបានរក្សាការសម្ងាត់ជាទីបំផុតតាមដែលអាចធ្វើទៅបាន។ ប្រសិនបើអ្នកប្តឹងសម្ងាតស្នើសុំភាពជាអនាមិក  នោះវានឹងត្រូវបានគោរពផ្តល់ជូន។

2. **<u>ការប្រកាសដល់បុគ្គលដែលពាក់ព័ន្ធ</u>**

- នីតិវិធីនៅនឹងកន្លែង ដូចនេះពាក្យបណ្តឹងរបស់បុគ្គលិកត្រូវបានដោះស្រាយដោយវិជ្ជាជីវៈ។ មិនផ្សព្វផ្សាយទៅខាងក្រៅ CFI ឬក៏ក្លាយទៅជាប្រធានបទនៃរឿងអាស្រូវនៅក្នុង CFI ដែលបង្កើតឲ្យមានបរិយាកាសអាប់អួ ឬ បង្កើតឲ្យមានការខូចកេរ្តិ៍ឈ្មោះទៅលើនរណាម្នាក់ដែលមិនអាចស្តារវិញបាន មុនពេលដែលពួកគេមានឱកាសត្រូវបានស៊ើបអង្កេត។
- សម្រាប់ការរំលោភបំពានលើកុមារដែលត្រូវបានសង្ស័យ ត្រូវរាយការណ៏ទៅកាន់បុគ្គលដែលពាក់ព័ន្ធអាចរួមបញ្ចូល មន្ត្រីធនធានមនុស្ស អ្នកគ្រប់គ្រងតាមផ្នែក នាយកប្រតិបត្តិ នាយកក្រុមប្រឹក្សាភិបាល ឬមន្ត្រីការពារកុមារ។
- អ្នកប្តឹងសម្ងាត់ មានសិទ្ធរំលងដោយមិនឆ្លងកាត់អ្នកគ្រប់គ្រងរបស់ពួកគេបាន ប្រសិនបើការចោទប្រកាន់ប្រឆាំងនឹងពួកគេ ហើយផ្តល់ព័ត៌មាននោះទៅកាន់ជួរអ្នកគ្រប់គ្រងផ្សេងទៀត ឬប្រាប់ដោយផ្ទាល់ទៅកាន់នាយកប្រតិបត្តិ ឬអ្នកដឹកនាំជាន់ខ្ពស់នៃក្រុមប្រឹក្សា។

3. **<u>ដឹងអំពីដំណើរការ</u>**

- មន្ត្រីស៊ើបអង្កេតពាក់ព័ន្ធ ត្រូវបានចាត់តាំងនឹងរៀបចំឯកសារដូចជា៖
  1) ព័ត៌មានលម្អិតពេញលេញនៃពាក្យបណ្តឹង
  2) ដំណើរការស៊ើបអង្កេតរបស់ពួកគេទាំងអស់
  3) ភស្តុតាងនៃការរកឃើញរបស់ពួកគេ
  4) របាយការណ៍ចុងក្រោយ ទៅលើការរកឃើញរបស់ពួកគេ។ ទាំងអស់នេះ នឹងត្រូវបានបង្ហាញផ្តល់ទៅកាន់អ្នកគ្រប់គ្រងដែលពាក់ព័ន្ធ ( អាស្រ័យលើអ្នកដែលកំពុងត្រូវបានគេស៊ើបអង្កេត) ។
- ក្នុងករណីធ្ងន់ធ្ងរជាងនេះ វាចាំបាច់តម្រូវអោយមានការព្យួរសមាជិកបុគ្គលិកដែលកំពុងត្រូវបានគេស៊ើបអង្កេតក្នុងកំឡុងពេលនីតិវិធីទាំងនេះ។

4. **<u>ព្យាយាមមិននៅតែរក្សាភាពអនាមិក</u>**

- ក្នុងកំឡុងពេលធ្វើការស៊ើបអង្កេត សំណួរចាំបាច់ណាស់ត្រូវបានសួរ។ ការបញ្ជូនព័ត៌មានជាលក្ខណៈអនាមិកធ្វើឲ្យការស៊ើបអង្កេតកាន់តែមានបញ្ហា។
- ការចោទប្រកាន់ជាអនាមិក ជាទូទៅមិនសូវគួរឱ្យទុកចិត្តទេ (ឧទាហរណ៍ ការផ្សព្វផ្សាយពាក្យចចាមអារ៉ាមអាក្រក់នៅក្នុងក្រុមអ៊ីមែល ឬក្នុងក្រុមបណ្ដាញសង្គម ហ្វេសបុក ដើម្បីធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់មិត្តរួមការងារ ។)

## 5. <u>ការយល់ដឹង អំពីផលវិបាកដែលអាចកើតមាន</u>

- នៅពេលដែលការចោទប្រកាន់ត្រូវបានរកឃើញថាជាការពិត បុគ្គលនៅក្នុងនីតិវិធីនៃការគ្រប់គ្រង អាចត្រូវបានស្នើសុំដាក់វិន័យ ឬការបញ្ចប់ការងារ ឬដាក់របាយការណ៍ទៅប៉ូលីស នៅកន្លែងដែលសកម្មភាពឧក្រិដ្ឋបានកើតឡើង។
- ក្នុងករណីដែលការចោទប្រកាន់មិនមានមូលដ្ឋានច្បាស់លាស់ មិនមានការចាត់វិធានការបន្តទៀតប្រឆាំងទាំងអ្នកប្តឹងសម្ងាត់ ដែលបានរាយការណ៍ដោយសុចរិត និងបុគ្គលដែលកំពុងត្រូវបានស៊ើបអង្កេតផងដែរ។

## 6. <u>ចំណេះដឹងនៃគោលការណ៍</u>

- ត្រូវប្រាកដថាមិត្តរួមការងារបច្ចុប្បន្ន និងថ្មីបានដឹងអំពីគោលការណ៍នេះ។
- ប្រសិនបើនរណាម្នាក់និយាយជាមួយអ្នកអំពីការសង្ស័យ សូមណែនាំពួកគេអំពីគោលការណ៍នេះ។
- ប្រសិនបើអ្នកឮពាក្យចចាមអារាម សូមរំលឹកអ្នកទាំងនោះអំពីគោលការណ៍នេះ និងជំហានសមស្របក្នុងការអនុវត្ត ហើយកាត់បន្ថយការនិយាយដើមគេក្នុងការិយាល័យ ដែលអាចធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់បុគ្គលម្នាក់ប្រសិនបើគ្មានមូលដ្ឋាន។

## 7. <u>ចូលចងចាំថា៖ CFI មានគោលការណ៍ “គ្មានការអត់ឱន” សម្រាប់ការបំពាន រួមទាំង SEA និងអំពើពុករលួយ។</u>

- CFI  ប្តេជ្ញាចិត្តក្នុងការធ្វើឲ្យមានស្តង់ដារខ្ពស់ដោយបើកចំហ តម្លាភាព និងគណនេយ្យភាព
- ចូលចំណាយពេលវេលាខ្លួនអ្នកដើម្បីយល់ដឹងទៅនឹង បទប្បញ្ញត្តិ គោលការណ៍ និងស្តង់ដារបស់ CFI

ឧបសម្ព័ន្ធ ១

ព័ត៌មានទំនាក់ទំនងសម្រាប់ នាយកក្រុមប្រឹក្សាភិបាលកំពូល:

**Susie Johnston**
+1 303.905.5966
sjohnston1736@gmail.com